# របៀបដំឡើង ក្តារចុចយូនីកូដខ្មែរ

អ្វីដែលអ្នកត្រូវការដើម្បីធ្វើឲ្យកុំព្យូទ័រអ្នកអាចប្រើ យូនីកូដខ្មែរ បាននោះអ្នកត្រូវមាន កម្មវិធីដំឡើងយូនីកូដខ្មែរ និង ស៊ីឌី Windows (បើអ្នកប្រើ Windows XP Service Pack 1 អ្នកត្រូវតែមាន ស៊ីឌី Windows XP Service Pack 1) ។ ជាដំបូងអ្នកត្រូវតែ ស្វែងរកឯកសារប្រតិបត្តិមួយ ដែលមានឈ្មោះថា KhmerUnicodeInstaller.exe ។ ឯកសារនេះជានិច្ចកាល ស្ថិតនៅទីតាំងជាមួយ ឯកសារដែលអ្នកកំពុងតែអាននេះដែរ ។ បន្ទាប់មកអ្នកគ្រាន់តែ ចុចពីរដង (ឬ សង្កត់គ្រាប់ចុច បញ្ចូល (Enter)) លើឯកសារនោះ វានឹងបើកហើយបង្ហាញផ្ទាំងដូចខាងក្រោម ៖

- *ចំណាំ ៖ អ្នកមិនត្រូវបញ្ចូលស៊ីឌី Windows នៅពេលនេះទេ ។*




សូមចុច Next ដើម្បីដំឡើង...




ជ្រើសទីតាំងដើម្បីដំឡើងឯកសារ ។ ប្រសិនបើអ្នកពេញចិត្ត
នឹងទីតាំងនេះហើយ សូមចុច Next




ប្រសិនបើមានប្រអប់ព្រមានដូចខាងលើ គ្រាន់តែចុច Yes ដើម្បីបន្ត




សូមរងចាំនៅពេលកម្មវិធីកំពុងដំឡើង...



ប្រអប់ខាងលើតម្រូវឲ្យអ្នក ប្រាប់ពីទីតាំងដែលអ្នកមានឯកសារ usp10.dll ។ ប្រសិនបើកុំព្យូទ័រអ្នកបានដំឡើង Microsoft Office 2003 ប្រអប់ខាងលើនឹងកំណត់វា ជាទីតាំងលំនាំដើម អ្នកគ្រាន់តែចុចប៊ូតុង Open តែប៉ុណ្ណោះ ។ តែបើអ្នកមិនបានដំឡើង Microsoft Office 2003 ទេ វានឹងកំណត់ C:\ ជាទីតាំងលំនាំដើម ។ ក្នុងករណីនេះ បើអ្នកបានទុកនៅទីតាំងផ្សេង សូមទៅទីតាំងនោះ រួចចុច ប៊ូតុង Open ។

សូមអ្នករង់ចាំពីរបីនាទី នោះនឹងមានប្រអប់មួយទៀត លេចចេញមក ។ អ្នកគ្រាន់តែចុចប៊ូតុង Close ជាការស្រេច ។







រួចហើយសូមអ្នកចុច Exit ។

ប្រសិនបើមាន ប្រអប់មួយលេចឡើង (Windows File Protection) ដែលតម្រូលឲ្យអ្នកបញ្ចូល ស៊ីឌី Windows សូមអ្នកចុច Cancel រួចចុច Yes ។ កុំបញ្ចូល ស៊ីឌី Windows ឲ្យសោះពីព្រោះវាបណ្ដាលឲ្យអ្នកមិនអាចប្រើយូនីកូដខ្មែរបាន ។






ក្នុងករណីមានការព្រមានលេចចេញមក ដូចខាងលើនេះ ការដំឡើងយូនីកូដខ្មែរបាន ជោគជ័យ ។ ជំហានបន្ទាប់ អ្នកគ្រាន់តែដំឡើងក្តារចុចភាសាខ្មែរ ។

អ្នកអាចដំឡើងក្តារចុចភាសាខ្មែរ ដោយចូលតាម Regional and Language Options ។ កម្មវិធីនេះអាចត្រូវចូលតាម ៖

១. ចុច Start ដែលនៅលើរបារការងារ

២. ជ្រើស Settings រួចជ្រើស Control Panel




៣. ចុចពីរដងលើ Regional and Language Options ។

បង្អួចដូចខាងក្រោមនឹងបង្ហាញ ។ សូមចុចលើផ្ទាំង Language រួចគូសធីក Install files for complex script and right-to-left languages (including Thai) ។ ប្រអប់ព្រមាននឹងបង្ហាញ គ្រាន់តែចុច OK ។ រួចហើយចុច ប៊ូតុង Details... ។






ចុចប៊ូតុង Add... ដើម្បីបន្ថែមក្ដារចុច

ក្នុងប្រអប់ Input language សូមអ្នកជ្រើសយក **Catalan** ជំនួសឲ្យ Cambodia ពីព្រោះបច្ចុប្បន្ននេះ មិនមានពាក្យ Cambodia ឲ្យជ្រើសទេ ។ ម៉្យាងទៀតដោយសារតែពាក្យ Catalan សរសេរកាត់ជា CA ហើយអក្សរកាត់នេះស្រដៀង Cambodia ដែលចាប់ផ្ដើមដោយ CA ។
អក្សរកាត់នេះនឹងត្រូវប្រើដើម្បីសម្គាល់ថា តេ ី ប្រភេទ  ក្ដា រចុចភាសាណាមួយដែលអ្នកកំពុងប្រើ ។
ក្នុងប្រអប់ Keyboard layout/IME សូមជ្រើសយក **KhmerOS – Khmer Unicode Keyboard 4.25** ។




បន្ទាប់មកចុច OK




នេះគឺជាផ្ទាំងដែលបានដំឡើងក្តារចុចយូនីកូដខ្មែរ ត្រឹមត្រូវ ។ ចុច OK ដើម្បីបញ្ចប់ការដំឡើង ។ លោកអ្នកត្រូវចុចប៊ូតុង OK របស់បង្អួច Regional and Language Options ។ ពេលនោះ Windows នឹងចម្លងឯកសារដែលត្រូវការ វាប្រហែលជាត្រូវការ ឲ្យអ្នកបញ្ចូលស៊ីឌី Windows ។ ពេលដំឡើងបានចប់សព្វគ្រប់អ្នកត្រូវតែ បិទកុំព្យូទ័រ និង បើកវាសារជាថ្មី ។

ខាងក្រោមនេះគឺជា រូបតំណាងក្តារចុច នៅលើរបារការងាររបស់ Windows ៖




នេះជារូបដំណាងក្តារចុចភាសាអង់គ្លេស




នេះជារូបដំណាងក្តារចុចភាសាខ្មែរ




អ្នកអាចប្តូរ ពីក្តារចុចភាសាមួយទៅក្តារចុចភាសាមួយទៀតបាន ដោយចុចលើរូបដំណាង និង ជ្រើសភាសាដែលត្រូវការ ។ អ្នកក៏អាចប្តូរ ក្តារចុច ដោយសង្កត់គ្រាប់ចុច ជំនួស (Alt) ព្រមគ្នាជាមួយនឹង ប្តូរ (Shift) ។ សូមសាកល្បងប្រើ ក្តារចុចយូនីកូដខ្មែរ ដែលអ្នកបានដំឡើងសាកមើល ។